ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៧២ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១. នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១.នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២១ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការកែសម្រួល អត្រាពន្ធគយ និងអាករលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន

- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- យោងតាមសំណូមពរការងារចាំបាច់

**សម្រេច**

**មាត្រា ១.-**

ត្រូវបានកែសម្រួលអត្រាអាករពិសេសលើមុខទំនិញនាំចូលចំនួន ១៩ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន រួមមាន ៖

- តម្លើងអត្រាអាករពិសេសពី ១០% ទៅ ២០% ចំនួន ១៣ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ៨៧០២.១០.១១ ៨៧០២.១០.១២ ៨៧០២.១០.១៣ ៨៧០២.១០.១៤ ៨៧០២.១០.២១ ៨៧០២.១០.២២ ៨៧០២.១០.២៣ ៨៧០២.១០.២៤ ៨៧០២.៩០.១១ ៨៧០២.៩០.១៩ ៨៧០២.៩០.៩១ ៨៧០២.៩០.៩៩ និង ៨៧១៦.៩០.៩៩ ។
- បន្ថយអត្រាអាករពិសេសពី ៣៣,៣៣% មក ១០% ចំនួន ០៦ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ២៧១០.១១.១១ ២៧១០.១១.១២ ២៧១០.១១.១៣ ២៧១០.១១.១៤ ២៧១០.១១.១៥ និង ២៧១០.១១.១៦ ។

**មាត្រា ២.-**

ត្រូវបានកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញចំនួន ២៧ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន រួមមាន ៖

- តម្លើងអត្រាអាករនាំចេញពី ១០% ទៅ ២០% លើមុខទំនិញចំនួន ២០ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ២៥១៥.១១.០០ ២៥១៥.២០.០០ ២៥១៦.១១.០០២៥១៦.២០.០០ ២៥១៦.៩០.០០ ២៥១៧.១០.០០ ២៥១៧.២០.០០ ២៥១៧.៤១.០០ ២៥១៧.៤៩.០០ ៧២០៤.១០.០០ ៧២០៤.២១.០០ ៧២០៤.២៩.០០ ៧២០៤.៣០.០០ ៧២០៤.៤១.០០ ៧២០៤.៥០.០០ ៧៤០៤.០០.០០ ៧៦០២.០០.០០ ៧៨០២.០០.០០ ៧៩០២.០០.០០ និង ៨០០២.០០.០០ ។
- បន្ថយអត្រាអាករនាំចេញពី ១០% មក ០% លើមុខទំនិញចំនួន ០៧ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ២៥២៣.១០.១០ ២៥២៣.១០.៩០ ២៥២៣.២១.០០ ២៥២៣.២៩.១០ ២៥២៣.២៩.៩០ ២៥២៣.៣០.០០ និង ២៥២៣.៩០.០០ ។

**មាត្រា ៣.-**

ត្រូវបានកំណត់ការប្រមូលអាករនាំចេញតាមរបៀប "ពន្ធគិតតាមឯកតា" លើមុខទំនិញជ័រកៅស៊ូចំនួន ៥៦ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន ដូចមានចែងក្នុង**ឧបសម្ព័ន្ធ**នៃអនុក្រឹត្យនេះ តាមរូបភាពដូចខាងក្រោម ៖

- ជាប់អាករនាំចេញ ៥០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញទាបជាង ២០០០ ដុល្លារអាមេរិកក្នុង ១ តោន ។
- ជាប់អាករនាំចេញ ១៥០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ២០០០ តែទាបជាង ៣០០០ ដុល្លារអាមេរិកក្នុង ១ តោន ។
- ជាប់អាករនាំចេញ ២០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ៣០០០ តែទាបជាង ៤០០០ ដុល្លារអាមេរិកក្នុង ១ តោន ។

- ជាប់អាករនាំចេញ ៣០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ៨០០០ ដុល្លារអាមេរិកឡើង ក្នុង ១ តោន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកចាត់ចែងអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១១ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ដើម្បីចុះហត្ថលេខា

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់សាលាខេត្ត និងសាលារាជធានី
- ដូចមាត្រា ៥
- រាជកិច្ច

| Head. | Tariff Code | បរិយាយមុខទំនិញ | Description of Goods |
|---|---|---|---|
| 40.01 | | កៅស៊ូធម្មជាតិ ជ័របាលាតា ជ័រ guttapercha ជ័រ guayule ជ័រល្មុត និងជ័រធម្មជាតិ ស្រដៀងគ្នាក្នុងទំរង់ដើម ឬជាផ្លាក ជាសន្លឹក ឬជាបង់ ។ | **Natural rubber, balata, gutta-percha, guayule, chicle and similar natural gums, in primary forms or in plates, sheets or strip.** |
| | 4001.10.11 | - - - កំហាប់សង់ទ្រីហ្វុយ | - - - Centrifuge concentrate |
| | 4001.10.19 | - - - ផ្សេងទៀត | - - - Other |
| | 4001.10.21 | - - - កំហាប់សង់ទ្រីហ្វុយ | - - - Centrifuge concentrate |
| | 4001.10.29 | - - - ផ្សេងទៀត | - - - Other |
| | 4001.21.10 | - - - គុណភាព Rss1 | - - - RSS Grade 1 |
| | 4001.21.20 | - - - គុណភាព Rss2 | - - - RSS Grade 2 |
| | 4001.21.30 | - - - គុណភាព Rss3 | - - - RSS Grade 3 |
| | 4001.21.40 | - - - គុណភាព Rss4 | - - - RSS Grade 4 |
| | 4001.21.50 | - - - គុណភាព Rss5 | - - - RSS Grade 5 |
| | 4001.21.90 | - - - ផ្សេងទៀត | - - - Other |
| | 4001.22.10 | - - - កៅស៊ូស្តង់ដាឥណ្ឌូណេស៊ី | - - - Standard Indonosian rubber SIR 3 CV |
| | 4001.22.20 | - - - កៅស៊ូស្តង់ដាឥណ្ឌូណេស៊ី ផ្សេងទៀត | - - - Other Standard Indonesian rubber |
| | 4001.22.30 | - - - កៅស៊ូស្តង់ដា ម៉ាឡេស៊ី | - - - Standard Malaysian rubber |
| | 4001.22.40 | - - - កៅស៊ូស្តង់ដា សិង្ហបុរី | - - - Specified Singapore rubber |
| | 4001.22.50 | - - - កៅស៊ូស្តង់ដា ថៃ | - - - Thai tested rubber |
| | 4001.22.90 | - - - ផ្សេងទៀត | - - - Other |
| | 4001.29.10 | - - - សន្លឹកចំអិនដោយខ្យល់ | - - - Air-dried sheet |
| | 4001.29.20 | - - - ជ័រក្រេបករ (តាលិច) | - - - Latex crepe |
| | 4001.29.30 | - - - ជ័រក្រេបបាត | - - - Sole crepe |
| | 4001.29.40 | - - - ជ័រក្រេបច្នៃឡើងវិញរាប់បញ្ចូលទាំងជ័រក្រេប | - - - Remilled crepe, including flat bark crepe |
| | 4001.29.50 | - - - ជ័រក្រេបផ្សេងទៀត | - - - Other crepe |
| | 4001.29.60 | - - - កៅស៊ូកែច្នៃគុណភាព | - - - Superior processing rubber |
| | 4001.29.70 | - - - កំណកកពុះកៅស៊ូខាងលើ | - - - Skim rubber |
| | 4001.29.80 | - - - កំទេចសំណល់កៅស៊ូ(ដើមឈើ ដី ឬ ផ្សេង) និងខាប់ឡាំ (cup lump) | - - - Scrap (tree, earth or smoked) and cup lump |
| | 4001.29.90 | - - - ផ្សេងទៀត | - - - Other |
| | 4001.30.11 | - - - ក្នុងទម្រង់ដើម | - - - In primary form |

| | | | |
|---|---|---|---|
| | 4001.30.19 | - - - ផ្សេងទៀត | - - - Other |
| | 4001.30.91 | - - - ក្នុងទម្រង់ដើម | - - - In primary form |
| | 4001.30.99 | - - - ផ្សេងទៀត | - - - Other |
| 40.02 | | កៅស៊ូសំយោគ និងកៅស៊ូចេញមកពីប្រេងផ្សេងៗក្នុងទំរង់ដើម ឬផ្លាក ជាសន្លឹក ឬជាល្បាយផលិតផលនៃទីតាំងលេខ ៤០.០១ ជាមួយផលិតផលនៃទីតាំងនេះ ក្នុងទម្រង់ដើម ឬជាផ្លាក ជាស្លឹក ឬជាបង់ដ៍ ។ | **Synthetic rubber and factice derived from oils, in primary forms or in plates, sheets or strip; mixtures of any product of heading No. 40.01 with any product of this heading, in primary forms or in plates, sheets or strip.** |
| | 4002.11.00 | - - ជ័រកៅស៊ូរាវ | - - Latex |
| | 4002.19.00 | - - ផ្សេងទៀត | - - Other |
| | 4002.20.00 | - កៅស៊ូ ប៊ុយតាឌីយ៉ែន ( BR ) | - Butadiene rubber (BR) |
| | 4002.31.00 | - - កៅស៊ូអ៊ីសូប៊ុយតែន- អ៊ីសូប្រ៉ែន (ប៊ុយទីល) ( IIR ) | - - Isobutene-isoprene (butyl) rubber (IIR) |
| | 4002.39.00 | - - ផ្សេងទៀត | - - Other |
| | 4002.41.00 | - - ជ័រកៅស៊ូរាវ | - - Latex |
| | 4002.49.00 | - - ផ្សេងទៀត | - - Other |
| | 4002.51.00 | - - ជ័រកៅស៊ូរាវ | - - Latex |
| | 4002.59.00 | - - ផ្សេងទៀត | - - Other |
| | 4002.60.10 | - - ក្នុងទម្រង់បឋម | - - In primary forms |
| | 4002.60.90 | - - ផ្សេងទៀត | - - Other |
| | 4002.70.00 | - កៅស៊ូអេទីឡែន - ប្រូពីឡែន- មិនលាយជាមួយឌីយ៉ែន (EPDM ) | - Ethylene-propylene-non-conjugated diene rubber (EPDM) |
| | 4002.80.10 | - - ល្បាយកៅស៊ូធម្មជាតិជាមួយកៅស៊ូសាំងតេទិករាវ | - - Mixture of natural rubber latex with synthetic rubber latex |
| | 4002.80.90 | - - ផ្សេងទៀត | - - Other |
| | 4002.91.10 | - - - ជ័រកៅស៊ូរាវ | - - - Latex |
| | 4002.91.90 | - - - ផ្សេងទៀត | - - - Other |
| | 4002.99.10 | - - - កៅស៊ូធម្មជាតិផ្សាំ នៃប៉ូលី(មេទីល- មេតាគ្រីលាត) | - - - Of poly(methyl-methacrylate)graft natural rubber |
| | 4002.99.90 | - - - ផ្សេងទៀត | - - - Other |
| 40.03 | 4003.00.00 | កៅស៊ូច្នៃឡើងវិញក្នុងទំរង់ដើម ឬជាផ្លាក ជាសន្លឹក ឬជាបង់ដ៍ | **Reclaimed rubber in primary forms or in plates, sheets or strip.** |
| 40.04 | 4004.00.00 | សំណល់ កំទេចកៅស៊ូ (ក្រៅពីកៅស៊ូរឹង) ម្សៅ និងគ្រាប់បានមកនោះ | **Waste, parings and scrap of rubber (other than hard rubber) and powders and granules obtained therefrom.** |
| 40.05 | | កៅស៊ូល្បាយមិនទាន់លាយស្ពាន់ធ័រ ក្នុងទំរង់ដើមជាផ្លាក ជាសន្លឹក ឬជាបង់ដ៍ | **Compounded rubber, unvulcanised, in primary forms or in plates, sheets or strip.** |
| | 4005.10.00 | - លាយជាមួយកាបោនប្លែក ឬស៊ីលីស | - Compounded with carbon black or silica |
| | 4005.20.00 | - ល្បាយ ល្បាយមិនរលាយក្រៅពីល្បាយនៃទីតាំងរងលេខ ៤០.០៥.១០ | - Solutions, dispersions other than those of subheading No. 4005.10 |

| | | | |
|---|---|---|---|
| | 4005.91.00 | - - ផ្ទាក សន្លឹក បង់ជ័ | - - Plates, sheets and strip |
| | 4005.99.00 | - - ផ្សេងទៀត | - - Other |
| **40.06** | | ទំរង់ផ្សេងទៀត (ឧទាហរណ៍ដើមមូលវែង ទិប និងប្រ៊ូហ្វ៊ីឡេ) និងវត្ថុ (ឧទា. ថាសកង់) ធ្វើពីកៅស៊ូមិនទាន់លាយស្ពាន់ធ័រ ។ | **Other forms (for example, rods, tubes and profile shapes) and articles (for example, discs and rings), of unvulcanised rubber.** |
| | 4006.10.00 | - ប្រ៊ូហ្វ៊ីឡេសំរាប់ចាក់កង់រថយន្តឡើងវិញ | - "Camel-back" strips for retreading rubber tyres |
| | 4006.90.00 | - ផ្សេងទៀត | - Other |
| **40.07** | 4007.00.00 | សសៃ និងខ្សែធ្វើពីកៅស៊ូលាយស្ពាន់ធ័រ | **Vulcanised rubber thread and cord.** |